ឆ្នាំទី ២ លេខ ១៦ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០២ រាជកិច្ច ទំព័រ ១០៥៤

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

Thouen / 2002

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :..........១១១.......បទ.ប្រក.

ភ្នំពេញ, ថ្ងៃទី២៩ ខែមេសាឆ្នាំ ២០០២

# ប្រកាស

## ស្ដីពីការ បង្កើតក្រុមការងាររៀបចំច្បាប់ពង្រៀង លើវិស័យទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារមួយ ដើម្បីរៀបចំច្បាប់ពង្រៀងស្ដីពីវិស័យទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្ដម គួយ គឹមស៊ា អនុរដ្ឋលេខាធិការ ប្រធាន

២-ឯកឧត្ដម ឡា ណារ៉ាត អនុរដ្ឋលេខាធិការ អនុប្រធាន

ាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ

ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០

ទូរសារ: (៨៥៥) ២៣-៤២៦៥៩២/៤២៦០១១

| | | | | |
|---|---|---|---|---|
| ៣-លោក | គង់ | សេង | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី | សមាជិក |
| ៤-លោក | គុប | សុខខួង | ប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត | សមាជិក |
| ៥-កញ្ញា | ឡេ | ម៉ាយគឿង | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | វៀល | ដារី | ប្រធានការិយាល័យ នៃ នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ៧-លោក | គិត | ស្រ៊ាង | មន្ត្រីការិយាល័យនិតិក្រម នៃ នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និង ទំនាក់ទំនងអន្តរជាតិ | សមាជិក |

**ប្រការ ២ :** ក្រុមការងារនេះមានភារៈកិច្ច ដើម្បីពិនិត្យ និង សំរាំងច្បាប់ស្តីពីវិស័យទូរគមនាគមន៍ ជាភាសាអង់គ្លេស និង ជាភាសាខ្មែរ រួចដាក់ជូន ឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និង សុំយោបល់សំរេច ។

**ប្រការ ៣ :** ក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ ឯកឧត្តមប្រធាន ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ខុទ្ទកាល័យ-អគ្គនាយកដ្ឋាន-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ-នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ និង សាម៉ីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ...លេខាធិការដ្ឋានព្រឹទ្ធសភា
- ...លេខាធិការដ្ឋានរដ្ឋសភា
- ...ការគណៈរដ្ឋមន្ត្រី
- ...សួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

ប្រការ ៥ " ដើម្បីអនុវត្តន៍ "

...កិច្ច

...សារ-កាលប្បវត្តិ

3